លេខ :...................                                          ភ្នំពេញ, ថ្ងៃទី        ខែធ្នូ ឆ្នាំ ២០០៧

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

**ជំរាបមក**

**លោក លោកស្រីប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីគ្រប់ខេត្ត ក្រុង**

**កម្មវត្ថុ** : គោលការណ៍ណែនាំស្តីពីការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ច

**យោង** : អនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច

ន័យដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូន**លោក លោកស្រី**ជ្រាបថា អនុលោមតាមអនុក្រឹត្យ លេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច ដីដែលនឹងត្រូវផ្តល់ជាសម្បទានដីសេដ្ឋកិច្ច ត្រូវតែជាដីដែលត្រូវបាន**ចុះបញ្ជីជាដីឯកជនរបស់រដ្ឋ** ។ ក្នុងន័យនេះ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បាន និងកំពុងខិតខំជំរុញដំណើរការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ តាមរយៈការចុះបញ្ជីដីរដ្ឋ សំដៅបំរើឱ្យការផ្តល់សម្បទានដី ទាំងសម្បទានដីសង្គមកិច្ច ទាំងសម្បទានដីសេដ្ឋកិច្ច និងសម្បទានផ្សេងៗទៀត ។

ដើម្បីកុំឱ្យរាំងស្ទះដល់ការវិនិយោគតាមរយៈសម្បទានដីសេដ្ឋកិច្ច ក្រសួងសូមធ្វើការណែនាំដល់ **លោក លោកស្រី**ប្រធានមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីយកចិត្តទុកដាក់ជំរុញការចុះបញ្ជីដីសម្បទាន ដោយត្រូវអនុវត្តតាមវិធីសាស្ត្រដូចខាងក្រោម :

**១_ការចុះបញ្ជីដីសម្បទាន ដែលបានចុះកិច្ចសន្យារួចហើយ :**

អនុលោមស្មារតីលិខិតលេខ ១១៥៦ ជនស/អសជ ចុះថ្ងៃ ០៣-១០-០៧ របស់ក្រសួង

រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ការចុះបញ្ជីដីសម្បទានសេដ្ឋកិច្ច ត្រូវធ្វើឱ្យបានសម្រេចក្នុងរយៈពេល **៣ខែ** ចាប់ពីថ្ងៃទទួលសំណើ ។ ដូចនេះ មន្ទីររៀបចំដែនដី នគរូប-នីយកម្ម សំណង់ និងសុរិយោដីខេត្ត-ក្រុង ដែលមានការវិនិយោគតាមរយៈសម្បទានដីសេដ្ឋ-កិច្ច ត្រូវ ៖

-ជូនដំណឹងទៅក្រុមហ៊ុនម្ចាស់សំណើឱ្យបោះបង្គោលរឹងមាំតាមព្រំដី

-លើកសំណើសុំមន្ត្រីបច្ចេកទេសចុះវាស់វែង និងកសាងប្លង់ដីសម្បទាន បន្ទាប់ពីបានបោះបង្គោលព្រំដីរួច ។ ទន្ទឹមនេះ ត្រូវត្រៀមមន្ត្រីជំនាញនៅមន្ទីរ ១រូប និងនៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុកពាក់ព័ន្ធ ១រូប ដើម្បីចូលរួមអនុវត្តការងារវាស់វែង ។ មុនថ្ងៃកំណត់ចុះវាស់វែង មន្ទីរត្រូវជូនដំណឹងទៅអាជ្ញាធរមូលដ្ឋានជ្រាប និងសហការចូលរួម ។

-ជូនប្លង់ដីកសាងបានទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ដើម្បីធ្វើចំណាត់ថ្នាក់ដី(បើដី មិនទាន់ជ្រះស្រឡះដោយជាប់ពាកព័ន្ធនឹងដីសាធារណៈរបស់រដ្ឋ ត្រូវលើកសំណើធ្វើអនុបយោគទីតាំងនេះ)

-បិទផ្សាយជាសាធារណៈនូវប្លង់ដីសម្បទានរយៈពេល ៣០ថ្ងៃ

-ចុះបញ្ជីដីសម្បទាននូវចំណែកដែលមិនពាក់ព័ន្ធនឹងដីសាធារណៈ និងដីប្រជាជន...។

## <u>២-ការចុះបញ្ជីដីសម្បទាន ដែលមិនទាន់បានចុះកិច្ចសន្យា</u> ៖

អ្នកវិនិយោគ ឬក្រុមហ៊ុន ត្រូវដាក់ពាក្យស្នើសុំវិនិយោគលើដី ដោយត្រូវភ្ជាប់ជាមួយនូវប្លង់បង្ហាញទីតាំងដី(ផែនទី) ការសិក្សាវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម(ESIA)។ មានជំរើសពីរ ៖

- **បើទីតាំងដីវិនិយោគ មានភាពស្មុគ្រស្មាញ** ត្រូវ ៖

-បិទផ្សាយជាសាធារណៈនូវប្លង់បង្ហាញទីតាំងដីសម្បទាន ដែលជាកម្មវត្ថុនៃសំណើវិនិ-យោគ នៅឃុំ ស្រុក ខេត្ត រយៈពេល **៣០ថ្ងៃ** ។

-ធ្វើអនុបយោគទីតាំងដីនេះ ចំពោះដីជាប់ពាក់ព័ន្ធនឹងដីសាធារណៈ

-ចុះកិច្ចសន្យាបណ្តោះអាសន្នរវាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអ្នកវិនិយោគ ឬក្រុមហ៊ុន ។ ក្នុងដំណាក់កាលនៃកិច្ចសន្យាបណ្តោះអាសន្ននេះ អ្នកវិនិយោគ ឬក្រុមហ៊ុន រួមជាមួយស្ថាប័នមានសមត្ថកិច្ច ត្រូវខិតខំដោះស្រាយ សម្រុះសម្រួលជាមួយអ្នក

ពាក់ព័ន្ធ ឱ្យជ្រះស្រឡះ ។

-លើកសំណើសុំមន្ត្រីបច្ចេកទេសពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ចុះវាស់វែង និងកសាងប្លង់ដីសម្បទានដែលមិនជាប់ពាក់ព័ន្ធនឹងដីសាធារណៈ និងដីប្រជាជន... ។

-ចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬសាលាខេត្ត)

-និងចុះកិច្ចសន្យាស្ថាពរ ។

◆ **បើទីតាំងដីវិនិយោគ មិនមានភាពស្មុគ្រស្មាញ**ទេ ត្រូវ ៖

-បិទផ្សាយជាសាធារណៈ នូវប្លង់បង្ហាញទីតាំងដីសម្បទាន ដែលជាកម្មវត្ថុនៃសំណើវិនិ-យោគ នៅឃុំ ស្រុក ខេត្ត រយៈពេល **៣០ថ្ងៃ** ។ ក្នុងរយៈពេលនេះ បើអាចធ្វើទៅបាន ត្រូវផ្សព្វផ្សាយ ទូលំទូលាយតាមកាសែត វិទ្យុ ទូរទស្សន៍

-ការសំរេចលើអនុក្រឹត្យស្តីពីការធ្វើអនុបយោគទីតាំងនេះ ចំពោះដីជាប់ពាក់ព័ន្ធនឹងដីសាធារណៈ

-កសាងប្លង់ដីសម្បទាន ដោយកាត់ចេញនូវផ្ទៃដីពាក់ព័ន្ធនឹងប្រជាពលរដ្ឋ(ករណីមិនអាចដោះស្រាយសម្រុះសម្រួលបានជាមួយប្រជាពលរដ្ឋម្ចាស់ដី) ដីព្រៃឈើ ទីវត្តអារាម ទីកប់ខ្មោច សំណង់វប្បធម៌ ដីរបស់សហគមន៍ជនជាតិដើមភាគតិច ផ្លូវថ្នល់ ផ្លូវរថភ្លើង និងដីចំណី ស្ទឹង ព្រែក ទន្លេ បឹងធម្មជាតិ...(លទ្ធផលនៃការបិទផ្សាយជាសាធារណៈ)

-ចុះបញ្ជីដីជាដីឯកជនរបស់រដ្ឋ(ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ឬសាលាខេត្ត-ក្រុង)

-និងចុះកិច្ចសន្យាស្ថាពរ ។

ដើម្បីឱ្យចំណេញពេលវេលា មុននឹងបិទផ្សាយជាសាធារណៈនូវប្លង់ដីសម្បទាន គណៈ-កម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត-ក្រុង ត្រូវធ្វើចំណាត់ថ្នាក់ដីរដ្ឋឱ្យហើយ រួចបញ្ចូលទិន្នន័យចំណាត់ថ្នាក់នេះក្នុងប្លង់ដីសម្បទានដែលត្រូវបិទផ្សាយ ។

សូម**លោក លោកស្រី**ប្រធានមន្ទីរ ទទួលនូវការរាប់អានដ៏ស្មោះអំពីខ្ញុំ ។

**ទេសរដ្ឋមន្ត្រី**

__**ចម្លងជូន៖**__

-ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

-សាលាខេត្ត-ក្រុង គ្រប់ខេត្ត-ក្រុង

-អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ

-ឯកសារ-កាលប្បវត្តិ